គួរលើកមកពិចារណាដែរ

# គោលការណ៍ និង កាលៈទេសៈ របស់យួន

## Principe et Circonstance du Vietnam

### I. គោលការណ៍ របស់យួន នៅស្រុកខ្មែរ

ស្រុកខ្មែរបច្ចុប្បន្ន ជាប្រទេសគ្មាន ឯករាជ្យ រស់នៅក្រោម អាណានិគមវៀតណាម។ គណបក្សប្រជាជន, ជាគណបក្សប្លន់អំណាច, រស់នៅក្រោម ឥទ្ធិពលយួន គ្រប់បែបយ៉ាង ដូចយ៉ាងៈ របៀបរបប ដឹកនាំរដ្ឋ, រចនាសម្ព័ន្ធ យោធា, ការគ្រិះរិះនយោបាយ បែបកុម្មុយនិស្ត និង មារយាទ ជាអ្នករណបដាច់ខាត។ល។ ដូច្នេះ ត្រូវចាំបាច់ រក្សា និង ការពារគោលការណ៍ របស់យួន នៅស្រុកខ្មែរ ដែលបែងចែក ជាពីរៈ គោលការណ៍ ដែលជាគ្រិះ និង គោលការណ៍ ដែលជា**ឧបសាធន** (accessoire)។

**ទី១. គោលការណ៍ ដែលជាគ្រិះ**

អ្នកដឹកនាំយួន គ្រប់ជំនាន់ មានគោលការណ៍ សំរាប់ជាតិគេច្បាស់លាស់ គឺ ពង្រិចពង្រីង ដែនដីវៀតណាម នៅឥណ្ឌូចិន ដែលគេចាត់ទុកជា «**ដែនដី សំរាប់អាយុជីវិត នៃជាតិសាសន៍យួន**»។ អ្នកដឹកនាំយួន ពីជំនាន់មួយ ទៅជំនាន់មួយ ត្រូវមាន កាតព្វកិច្ច ពង្រិចពង្រីង ទឹកដី សំរាប់ប្រជាជនយួន ដូច្នេះ ត្រូវចាំបាច់ ការពារដាច់ខាត អាណានិគមជនយួន នៅគ្រប់ទីកន្លែង ដែលជនជាតិយួន ទៅរស់នៅ។ គោលការណ៍នេះ ខ្មែរយើងដឹងឮ និង ឃើញ ជាក់ច្បាស់ណាស់ នៅក្នុង ប្រវត្តិសាស្ត្រជាតិ របស់ខ្លួន ដែលលោក នួន-ឃឿន ឲឈ្មោះថា «ដំណើរឆ្ពោះទៅទិសខាងលិច» ដែលជា បណ្តាំ ជាអមតៈ សំរាប់ជនជាតិខ្មែរ ជំនាន់ក្រោយ។ គោលការណ៍នេះ បានជ្រាបក្នុង ជម្រៅ នៃអារម្មណ៍ របស់ជនជាតិយួន ហើយក្លាយជា មនោគមវិជ្ជាជាតិ ឬ ព្រលឹងជាតិ ហើយពង្រឹងដោយ ផ្ទាំខ្លាំង គឺ ជោគជ័យ ជានិច្ច របស់ប្រជាជាតិវៀតណាម តាំងពី សត្តវត្សទី១៣ មកម្លេះ៖ ជោគជ័យ លើមហាចិន, លើនគរចម្ប៉ា,លើលាវ និង លើកម្ពុជា។ ចម្បាំង ដែលមានកើតឡើង នៅក្នុងស្រុកយួន រវាងយួន និង យួន គឺ សុទ្ធជាចម្បាំង ស្វែងរក ឯកភាពតែមួយ និង ឯករាជ្យ យួន ជានិច្ច។

នៅក្នុងស្រុកខ្មែរបច្ចុប្បន្ន  សំរាប់គណបក្សកុម្មុយនិស្តយួន គោលការណ៍នេះ ជាអាយុជិវិត របស់ជាតិសាសន៍យួនផង និង អំណាចកុម្មុយនិស្ត នៅប្រទេសវៀតណាមផង ព្រោះកម្ពុជា ជាដីថ្មី សំរាប់ចិញ្ចឹមជីវិត នៃប្រជាជនយួន ដែលកាន់តែកើនច្រើនឡើងៗ ដែលនាំបង្កើត ជាបញ្ហា រស់នៅ ក្នុងដែនកដីវៀតណាមសព្វថ្ងៃ, ដូច្នេះ ការហូរចូល នៃជនជាតិយួនមកក្នុងប្រទេសកម្ពុជា ជាការអនុវត្តន៍ នៃគោលការណ៍ ដែលជាគ្រិះ របស់អ្នកដឹកនាំយួន ដើម្បីពង្រិច «ដែនដី សំរាប់អាយុជិវិត នៃជាតិសាសន៍យួន»។ ចំពោះអ្នកដឹកនាំយួន ទឹកដីប្រទេសកម្ពុ

ជា ជាទឹកដី ដណ្ដើមបាន តាមល្បិចនយោបាយ មិនមែន ជាជោគជ័យយោធា ដូចក្នុងឆ្នាំ១៩៧៩ នោះទេ តែគេ ទុកជានិច្ច «ជោគជ័យឆ្នាំ១៩៧៩» ជាមូលដ្ឋាន ដើម្បីបំរើ ល្បិចនយោបាយ សំរាប់ជ័យជំនិះផ្ដាច់ព្រ័ត្រ។ ក្នុងល្បិច នេះ អ្នកដឹកនាំយួន ត្រូវការ បាវព្រាវ, អ្នកចូលដៃ, អ្នកសំរួលការ (facilitateur) ឬ អ្នកបង្គ្រប់កិច្ច និង អ្នកហៃអើ សំរាប់បំរើ ហេតុ នៃល្បិច។

**បាវព្រាវ**៖ គឺជា អតីតអ្នកដឹកនាំ សាធារណរដ្ឋ កម្ពុជាប្រជាមានិត មាន ហ៊ុន-សែន, ជា-ស៊ីម, និង ហេង-សំរិន ជាមេកោយ។ បាវព្រាវ ជាផលា នៃថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ កើតឡើង ដើម្បី បំរើ គោលការណ៍ ជាគ្រឹះ របស់យួន ជាអាយ៉ងយួនដាច់ថ្លៃ រស់ ជាយួន ដើម្បីយួន តែប៉ុណ្ណោះ។ បើគ្មាន ពួកនេះ គឺយួន ពុំអាចជាន់ លើដីខ្មែរបាន ងាយ នោះឡើយ។ ហេតុនេះ ខ្មែរយើង មិនត្រូវ គិតថា ពួកបាវព្រាវនេះ មិនសូវមាន សារៈសំខាន់ ក្នុងតួនាទី បំផ្លាញជាតិ ដើម្បីយួននោះឡើយ។

**អ្នកចូលដៃ**៖ គឺជា សពាស្ដេចសីហនុ និង អ្នកសីហនុនិយម សព្វថ្ងៃ មានទ្រង់ រណប្ញទ្ធិ ជាតំណាងនយោបាយ ខ្យល់ និង ស្ដេចសីហមុនី ជាតំណាងបុគ្គលសីហនុ។ ពួកនេះ យកសសរ កន្លោង រាជានិយម មកធ្វើ ជាជន្លង់ ទ្រ គោលការណ៍ជាគ្រឹះ របស់យួន ជាអ្នកបំរើ ដើម្បីអត្ថប្រយោជន៍ រស់ជាខ្មែរ តែមាន ខួរតូច ជាយួន។ បើគ្មាន ពួក នេះ ពួកបាវព្រាវយួន ពិបាករស់ ជាយួន ដើម្បីយួន នៅក្នុងស្រុកខ្មែរ ព្រោះពួកនេះ ជារាំងនន រាជានិយម សំរាប់ លំអ រដ្ឋរបស់គណបក្សប្រជាជន។

**អ្នកសំរួលការ ឬ អ្នកបង្គ្រប់កិច្ច**៖ គឺជា គណបក្ស ធ្វើជាអ្នកប្រឆាំង សព្វថ្ងៃ មានឈ្មោះ គណបក្សសង្គ្រោះ ជាតិ ដែលមាន សម-រង្ស៊ី និង កឹម-សុខា ជាមេដឹកនាំ មាន សុន-ឆៃ, យិម-សុវណ្ណ, យែម-បុញ្ញរិទ្ធ ជាជើងសារ ជា សមាជិក ក្រុមការងារ សំរាប់ធ្វើការចរចារ ជាមួយ ពួកបាវព្រាវ ដើម្បី បានទទួលកំទេចអំណាច និង ឯក សិទ្ធិ នៅក្នុង របបចោរម៉ែទ (kleptocratie) ជាអ្នកលំអ របបមួយដែរ យកសសរកន្លោង ប្រជាធិបតេយ្យ មកធ្វើ ជាជន្លង់ ទ្រគោលការណ៍ជាគ្រឹះ របស់យួន។ បើគ្មានពួកនេះ គណបក្សប្លន់អំណាច នៅស្រុកខ្មែររ ពុំអាច យកការ បោះឆ្នោត គ្មានសេរី គ្មានយុត្តិធម៌ មកធ្វើជា ឧបករណ៍ សំរាប់បន្ត កាន់អំណាចផ្ដាច់ការ នៅស្រុកខ្មែរ បាននោះ ឡើយ។

**អ្នកហៃអើ**៖ ជាពួកអ្នកគាំទ្រ ពួកអ្នកចូលដៃផ្កាប់មុខ និងអ្នកបង្គ្រប់កិច្ច។ ចេះស្ដាប់ និង ជឿ តែលើសំដី តែមិន តាមមើល សកម្មភាពពិត របស់អ្នកដឹកនាំខ្លួន។ ពួកនេះ ជាអ្នកចាំទះដៃ នៅក្នុងសម័យប្រជុំ ជាអ្នកជួយ ជា ថវិកា តែមិនដែលគិត ពីប្រសិទ្ធិភាព សកម្មភាព នៃអ្នកទទួលជំនួយ គឺនាំគ្នាជួយ សកម្មភាព ដូចនាំគ្នាធ្វើ បុណ្យ រកកុសលបុណ្យ សំរាប់ជាតិក្រោយ។ បើគ្មានពួកនេះ ពួកអ្នកចូលដៃ ឬ អ្នកបង្គ្រប់កិច្ច មិនអាច កុហក ខ្មែរអ្នករងគ្រោះ នៅក្នុងស្រុក ថាខ្លួនមាន ការគាំទ្រ និង ជំនួយ ពីខ្មែរ នៅក្រៅប្រទេស។

២. **គោលការណ៍ ដែលជាឧបសាធន** (accessoire)

យួន បង្កើត ឲមានសណ្ឋានខ្លះ នៃសកម្មភាពប្រឆាំង ដែលមាននៅក្នុង លទ្ធិប្រជាធិបតេយ្យពហុបក្ស ចារនៅ ក្នុង រដ្ឋធម្មនុញ្ញខ្មែរ ដើម្បី ឲស្រប នឹងច្បាប់។ សកម្មភាពប្រឆាំង ដែលជ្រើសរើសនេះ យួន គេទុក ជាគោល ការណ៍ ជាឧបសាធន។ យួនជាអ្នកជ្រើសរើស អ្នកប្រឆាំង នៅក្នុងស្រុកខ្មែរ ដោយឈរ លើ លក្ខណវិនិច្ឆ័យ

(critère) អ្នកសីហនុនិយម។ ក្រៅពីនេះ យួន មិនអនុញ្ញាតិ ដោយប្រើមធ្យោបាយគ្រប់បែបយ៉ាង សំរាប់បន្ទប់ខ្យល់ មិនឲអ្នកប្រឆាំង ដ៏ទៃទៀត អាចកើតមានឡើងបាន នៅក្នុងស្រុកខ្មែរ, ឧតាហរណ៍ជាក់ស្តែងគឺករណីយ លោក ម៉ម-សាណង់-ដូ។ គោលការណ៍ ជាឧបសាធននេះ ជាមធ្យោបាយ ដើម្បី ពង្រឹង គោលការណ៍ការណ៍ ជាគ្រិះ ដូចជា អាហារ សំរាប់ចិញ្ចឹមជីវិត។ ជាមធ្យោបាយកុម្មុយនិស្ត សំរាប់រស់ នៅក្នុងរដ្ឋ ដែលជា អតីតរដ្ឋកុម្មុយនិស្ត ប្រែក្រឡា ជារដ្ឋសេរីនិយម ក្រោមការដឹកនាំ នៃអ្នកដឹងនាំចាស់ ដែលជា អតីត អ្នកកុម្មុយនិស្តនិយម។

បច្ចុប្បន្ននេះ យួនបានជ្រើសរើស សម-រង្សី និង កឹម-សុខា ធ្វើជាអ្នកប្រឆាំង នឹងអាយ៉ង របស់ខ្លួន។បុគ្គលទាំងពីរនេះ ជាអ្នកសីហនុនិយម យកសីហនុ ជាលំនាំនយោបាយដាច់ខាត ដូច្នេះ ត្រូវនាំគ្នា ការពារ របបរាជានិយម ដែលជា វាំងនន នៃអាយ៉ងយួន។ យួនអនុញ្ញាតឲ សម-រង្សី រិះគន់បានខ្លះ ដល់របៀបដឹកនាំរដ្ឋ តែហាមមិនឲ ប៉ះពាល់ដាច់ខាត ដល់មេដឹកនាំ និង គោលការណ៍ជាគ្រិះ របស់យួន។ នៅក្នុងគោលការណ៍ ជាឧបសាធននេះឯងហើយ បានជា សម-រង្សី នៅតែបន្ត ធ្វើការចរចារ ជាមួយគណបក្សប្រជាជនជានិច្ច និង មិនទុកបញ្ហាអាណានិគមជនយួន ជាគ្រោះអាសន្ន ដល់ប្រជាជាតិខ្មែរនោះឡើយ។ សម-រង្សី សព្វថ្ងៃ យក យល់សប្តិរបស់ខ្លួន ថាខ្លួនមានការគាំទ្រ ពីចិនកុម្មិយនិស្ត តែតាមការពិត មកដល់សព្វថ្ងៃនេះ អ្នកផ្លូវការចិន គេមិនដែលឲ ខ្លួនជួប ជាសម្ងាត់ក្តី ចេញមុខក្តី ម្តងណាមួយឡើយ បើបានជួបចិន គឺបានតែជួប ពួកជើងសារជំនួញ (courtier) ធ្វើការឲយួន មកនិយាយបោកប្រាស់ ថាត្រូវធ្វើនេះ ត្រូវធ្វើនោះ គឺច្បាស់ជាមានមហាចិន នៅពីក្រោយជាពុំខាន។ ល្បែងនេះ ពួកជើងសារជំនួញចិន គេយកមកលេង តាំងពីឆ្នាំ១៩៧៩ មកម្លេះ ហើយបច្ចុប្បន្ននេះ យួន យកទង្វើនេះ មកបញ្ចូល នៅក្នុង គោលការណ៍ជាឧបសាធន របស់គេ ដើម្បីបោកប្រាស សម-រង្សី ដែលជា, មនុស្សស្រាលស្រាប់ផង, ឲរស់តែ នៅក្នុង យល់សប្តិ បែបនេះជានិច្ច។

យួន ជ្រើសរើស សមរង្សី  ព្រោះបុគ្គលនេះ ជាអ្នកសីហនុនិយម ផ្កាប់មុខ តែយួន វាមាន លក្ខណវិនិច្ឆ័យ មួយទៀត ក្នុងជម្រើសនេះ គឺ ការខ្វះ «វប្បធម៌នយោបាយ» និង «ការពិសោធន៍នយោបាយ» របស់ សម-រង្សី ដោយសារ បុគ្គលនេះ រស់នៅតែ ក្រោមឥទ្ធិពលសីហនុ មិនដែលយក ឬក៏ មិនដែលហ៊ានយក ប្រាជ្ញាខ្លួនមកត្រិះរិះ សំរាប់ការលូតលាស់ នៃវប្បធម៌នយោបាយ របស់ខ្លួន។ កង្វះនេះ ដែលនាំឲខួរក្បាល សម-រង្សី ឡើងរឹង លែងប្រែប្រួលបាន ក្នុងផ្នែកវប្បធម៌នយោបាយ ហើយ ការពិសោធន៍នយោបាយ របស់ខ្លួន, ក្នុងរយៈវេលា២៣ឆ្នាំនេះ (១៩៩១-២០១៤), គឺនៅត្រឹមតែ «គោរពគោលការណ៍នយោបាយ នៃសម្តេចសីហនុ ដែលខ្លួនទុកជា វរៈបិតាជាតិខ្មែរ» (Sic)។មកដល់សព្វថ្ងៃ សមរង្សី ចេះនិយាយតែពាក្យមួយមាត់គត់ គឺ ធ្វើតាមនយោបាយ ស្តេចសីហនុ។

## II. កាលៈទេសៈ របស់យួន នៅស្រុកខ្មែរ

កាលៈទេសៈ ដែលយួន អាចយក គោលការណ៍ជាគ្រិះ របស់វា មកអនុវត្តន៍ នៅក្នុងស្រុកខ្មែរបាន មានច្រើន តែយើង គ្រាន់តែលើកជាគោល យកវា មករំលឹក ដល់ខ្មែរណា ដែលធ្លាប់ដឹងរួចហើយ ហើយ ជំរាបជូន ដល់ខ្មែរ

ណា ដែលមិនធ្លាប់ដឹងពុះ

- ក្នុងរជ្ជកាលព្រះបាទ ជ័យជេដ្ឋាទី២ (១៦១៩-១៦២៧) ៖ ស្តេចអង្គនេះ មានមហេសីយួន ព្រះនាម កូជិន ជាបុត្រីស្តេចយួន។ ព្រះនាង បានស្នើរដល់ព្រះស្វាមី សុំអនុញ្ញាត ឲជនជាតិយួន មករស់នៅ ជាបណ្តោះអាសន្ន ក្នុងខេត្តព្រៃនគរ។ ការអនុញ្ញាត របស់ព្រះបាទ ជ័យជេដ្ឋាទី២ ក៏ជាការផ្តើម នៃជំនន់រលា (déluge) នៃជនជាតិយួន មកក្នុងទឹកដីខ្មែរ។ ក្នុងឆ្នាំ១៦៩៨ យួនដូរឈ្មោះ ខេត្តព្រៃនគរ ជា «សៃហ្គន» ឈ្មោះនេះ អាណានិគមបារាំង យកមកប្រើ ជាផ្លូវការ ទោះបីបារាំងដឹកច្បាស់ថា ខ្មែរ នៅតែហៅខេត្តរបស់ខ្លួនថា ព្រៃនគរយ៉ាងណាក៏ដោយ។

- ក្នុងសម័យអាណានិគមបារាំង ជាពិសេស នៅពេលដែល អាជ្ញាបារាំង បង្កើត អង្គភាព «ឥណ្ឌូចិន» ដែលជាអង្គភាព អភិបាលផង និង អង្គភាព នយោបាយផង របស់អាណានិគមបារាំង។ ឥណ្ឌូចិននេះ ប្រមូលផ្តុំ ប្រទេសបី ខ្មែរ, យួន, លាវ ក្នុងអង្គភាពតែមួយ ដើម្បីសំរួល ការត្រួត្រា របស់អាជ្ញាធរអាណានិគម តែវា ជាគ្រោះថ្នាក់ធំណាស់ ចំពោះ ប្រទេសខ្មែរ និង លាវ ព្រោះបារាំង អនុញ្ញាត ជាផ្លូវការ ឲជនជាតិយួន ដែលមានចំនួនច្រើនលើសលុប លើប្រជាជនខ្មែរ និង លាវ មករស់នៅ ក្នុងស្រុកខ្មែរ និង លាវ។ ទឹកដៃកម្ពុជាក្រោម បានក្លាយជាទឹកដីឥណ្ឌូចិនបារាំង ដែលមានជនជាតិយួន និង ចិន មករស់នៅកុះករ ហើយជនជាតិខ្មែរ ក៏ក្លាយជាជនជាតិភាគតិច រស់នៅលើទឹកដី ដែលខ្លួនជាម្ចាស់ស្រុក។ នៅក្នុងទឹកដីខ្មែរកណ្តាល បារាំងជួយជម្រុញ ជនជាតិយួន ចិន ឲមករស់នៅ ជាច្រើន ក្នុងខេត្ត កណ្តាល, ព្រៃវែង, នៅជុំវិញបឹងទន្លេសាប និង តាមច្រាំងទន្លេមេកុង។

យោងតាមស្ថិតិ ក្នុងឆ្នាំ១៩៧០ ជនអន្តោប្រវេសយួន មានចំនួន ប្រមាណ ៤៥០ ០០នាក់។ 2/3 រស់នៅក្នុងខេត្តកណ្តាល, 4/5 រស់នៅក្នុងខេត្តព្រៃវែង។

ឯចំណែក ជនអន្តោប្រវេសចិនវិញ ក្នុងឆ្នាំ១៩៧០ មានចំនួន ប្រមាណ ៥០០ ០០០នាក់។ គួរកត់សំគាល់ថា ក្នុងឆ្នាំ១៩៥០ នៅស្រុកខ្មែរ មានជនជាតិចិន មករស់នៅ មានចំនួន ២១៨ ០០០នាក់ រួចស្រេចហើយ។

- សន្និសិត នៅទីក្រុងស៊ីណែវ ក្នុង១៩៥៤ សំរាប់ដោះស្រាយ ជាបណ្តោះអាសន្ន នៃបញ្ហាសង្គ្រាម រវាងបារាំង នឹងយួនកុម្មុយនិស្ត ទទួលស្គាល់ លើឆាកអន្តរជាតិ ដោយមិនបាច់ចែងឲច្បាស់ (implicitement) ទឹងដីកម្ពុជាក្រោម ជាអង្គភាព នៃដែនដី របស់ប្រទេសវៀតណាម ព្រោះទឹកដីកម្ពុជាក្រោម ត្រូវបានគេ បញ្ចូល នៅក្នុងសាធារណៈរដ្ឋវៀតណាមខាងត្បូង។ គេដឹងថា ទឹកដីកម្ពុជាក្រោមនេះ ក្នុងឆ្នាំ១៩៤៩[1] រដ្ឋសភាបារាំង បានបោះឆ្នោត កាត់ផ្តាច់ ពីរាជាណាចក្រកម្ពុជា រួចស្រេចមកហើយ។ គណៈប្រតិភូខ្មែរ ដែលបានចូលប្រជុំ ក្នុងសន្និសិតទីក្រុងស៊ីណែវ គ្មានប្រតិកម្មអ្វី ក្នុងរឿងបង្កើតសាធារណរដ្ឋវៀតណាមខាងត្បូង ដែលមានទឹកដីកម្ពុជាក្រោមនៅក្នុងនោះទេ។

- នយោបាយសម្តេចសីហនុ ផ្អៀងទៅលើ ចិន/យួនកុម្មុយនិស្ត នៅក្នុងសង្គ្រាមវៀតណាមលើកទី២ នាំឲប្រទេសខ្មែរ ប្រែក្លាយជា មូលដ្ឋានសឹក របស់ទ័ពយៀកកុង និង សាធារណរដ្ឋសង្គមនិយមវៀតណាម សំរាប់ធ្វើសង្គ្រាម

[1] ឆ្នាំ១៩៤៩ ជាឆ្នាំ ដែលបារាំងគេទទួលស្គាល់ប្រទេសខ្មែរ ជាប្រទេសឯករាជ្យ នៅក្នុងសហភាពបារាំង លើកលែងតែ វិស័យ នយោបាយការបរទេស, យោធា និង យុត្តិធម៌ គឺឋិតនៅក្រោមអំណាចបារាំងនៅឡើយ។ នៅក្នុងឆ្នាំនេះដែរ សម្តេចសីហនុ បានរំលាយរដ្ឋសភា ដែលមានគណបក្សប្រជាធិបតេយ្យ ជាគណបក្សភាគច្រើន មាននិន្នាការនយោបាយ ប្រឆាំងនឹងនយោបាយទ្រង់ ក្នុងវិស័យទៀមទារឯករាជ្យពីបារាំង។ ក្នុងឆ្នាំនោះដែរ លោក អៀវ-កើស វរៈជននៃគណបក្សប្រជាធិបតេយ្យ និង ជាអតីតប្រធានរដ្ឋសភា ត្រូវបានគេលួចធ្វើឃាតលោក ដោយចោលគ្រាប់បែកដី សម្លាប់លោក។

ពង្រឹងចលទ្ធិកុម្មុយនិស្ត នៅវៀតណាម ទល់នឹងអាមេរិកាំង និង សាធារណរដ្ឋវៀតណាមខាងត្បូង ជាអ្នកការពារសេរីភាព នៃប្រជាជនយួន ប្រឆាំងនឹងកុម្មុយនិស្ត។ ការឈប់ទទួលជំនួយ យោធាអាមេរិកាំង ជាការសំរេចមិនល្អមួយ របស់ស្ដេចសីហនុ ដែលនាំឲ កងទ័ពខ្មែរ ខ្វះមធ្យោបាយ ធ្វើវប្បនីយកម្ម កងទ័ព ដើម្បីទប់ទល់ ជាយថាហេតុ នៃការគំរាមកំហែង កងទ័ពយួនកុម្មុយនិស្ត ដែលធ្លាប់មាន តាំងពីសង្គ្រាមលើកទី១ នៅវៀតណាមមកម្លេះ។ ការកំហែងនេះ វាគ្រាន់តែ ដេកសម្ងំចាំឪកាសថ្មី ដើម្បីឈ្លានពាន កម្ពុជា តែប៉ុណ្ណោះ។

- ឪកាសថ្មីនោះ មានកើតឡើង នៅក្នុងឆ្នាំ១៩៧០ នៅពេលដែលសភាជាតិខ្មែរ ទម្លាក់ស្ដេចសីហនុ ពីតំណែងប្រមុខរដ្ឋអស់មួយជីវិត។ ដើម្បីឆ្លើយតប នឹងសេចក្ដីសំរេច របស់សភាជាតិ ស្ដេចសីហនុ បានអំពាវនាវ ឲយួនកុម្មុយនិស្ត ឈ្លានពានកម្ពុជា តាមផ្លូវសឹក ដើម្បីដណ្ដើមអំណាច ថ្វាយព្រះអង្គវិញ។ ព្រះអង្គ ជាអ្នកបង្កជម្លោះ ជាមួយ នឹងរាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ដឹកនាំដោយ លោក លន់-នល់ ដែលជារាជរដ្ឋាភិបាល របស់ព្រះអង្គ ក្នុងឋានៈព្រះអង្គ ជាប្រមុខរដ្ឋ ព្រោះ ព្រះអង្គ មិនព្រមជួប ជាមួយគណៈប្រតិភូ ចាត់តាំងរួម ដោយមាតាព្រះអង្គ ជាមួយនឹង លោកលន់-នល់ ដើម្បីថ្វាយជូន នូវព័ត៌មានពិត ដែលមានកើតឡើង នៅក្នុងស្រុក គឺហេតុ នៃបាតុកម្ម របស់ប្រជាជន ប្រឆាំងនឹង វត្តមានកងទ័ពយៀកកុង នៅក្នុងដែនដីខ្មែរ។ ការមិនព្រមជួបនេះ នាំឲព្រះអង្គ ទុកជាតិដោយខ្លួនឯង ជាសត្រូវ ចោទប្រកាន់រាជរដ្ឋាភិបាល ថាមានបំណងចង់ធ្វើរដ្ឋប្រហារ គំរាមកំហែង ថាជាស្ថាប័នក្បត់ជាតិ ដូច្នេះព្រះអង្គ នឹងកាត់ទោសប្រហារជីវិត សមាជិក ជាដាច់ខាត នៅពេលព្រះអង្គ យាងវិលត្រឡប់ពីបរទេសមកវិញ។ ការច្រានចោល របស់ស្ដេចសីហនុ នូវនយោបាយការពារ បូរណភាពដែនដីកម្ពុជា របស់រាជរដ្ឋាភិបាល ជាអំពើក្បត់ជាតិ ដែលជាហេតុ ឲសភាជាតិ ទម្លាក់ព្រះអង្គ ពីដំណែង ប្រមុខរដ្ឋអស់មួយជីវិត។ កំហឹងប្រឆាំងនឹងជាតិខ្លួនឯង នាំឲស្ដេចសីហនុ យកការសងសឹក ជាមធ្យោបាយ ស្រែករកទ័ពយៀងកុង ឲជួយព្រះអង្គ ដែលវា មានមូលដ្ឋានសឹកនៅក្នុងស្រុកខ្មែររួចស្រេចទៅហើយ តាមការអនុញ្ញាតិរបស់ព្រះអង្គនោះឯង ឲវាយកងទ័ពជាតិខ្មែរតែម្ដង។ សង្គ្រាមបានផ្ទុះឡើង នៅស្រុកខ្មែរ ដែលមានស្ដេចសីហនុ, ខ្មែរក្រហម និង យួនកុម្មុយនិស្ត ជាអ្នកបង្កបង្កើត ដូច្នេះនោះឯង។ សង្គ្រាមនេះ នាំឲយួនកុម្មុយនិស្ត មានឥទ្ធិពល ក្នុងនយោបាយផ្ទៃក្នុង របស់ខ្មែរ រហូតមកក្នុងសម័យ កម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មកយួន វា វាយរំលាយ របបប្រល័យពូជសាសន៍នេះ បានយ៉ាងងាយស្រួលបំផុត ព្រោះជារបប គ្មានប្រជាពលរដ្ឋខ្មែរ ជាកម្លាំងការពារជាតិ។

- ចាប់ពីថ្ងៃទី៧មករាឆ្នាំ១៩៧៩ ជាថ្ងៃដែល កងទ័ពសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលមកកាន់កាប់ស្រុកខ្មែរ អ្នកដឹងនាំខ្មែរ គ្រប់និន្នាការនយោបាយ ខ្វះសមត្ថភាព ការពារជាតិខ្មែរ រហូតមកដល់សព្វថ្ងៃនេះ។ កិច្ចព្រមព្រៀងសន្តិភាព នាថ្ងៃទី២៣តុលាឆ្នាំ១៩៩១ គ្រាន់ជាពេលវេលាមួយ សំរាប់ជាតិខ្មែរ តែកង្វះសម្បជញ្ញជាតិនៃអ្នកដឹកនាំ មានសីហនុជាអាទ៍ នាំឲ យួនកុម្មុយនិស្ត ក្លាយ ជាម្ចាស់នយោបាយខ្មែរ ទាញកម្ពុជា ឲចូលទ្រុងតណ្ហចិន ឲក្លាយជាកម្ពុជាក្រោម ជាប្រទេស ដែលមានប្រជាជនយួន ជាប្រជាជនភាគច្រើន ទុកខ្មែរ ជាអនុប្រជាជន រស់ដើម្បីកសាង «មហាវៀតណាម»។

## សេចក្ដីសសន្និដ្ឋាន

បុរាណភាសិតខ្មែរមួយថ្លែងថា «យួនមិនដែលចោលពត់ ខ្មែរមិនដែលចោលចែចូវ» (ន័យទី២)[2] គឺចាស់បុរាណខ្មែរ ចង់ផ្ដែផ្ដាំ ដល់ខ្មែរជំនាន់ក្រោយថា ខ្មែរចេះតែឈ្លោះគ្នា សម្លាប់គ្នា ឥតប្រយ័ត្ន គិតថា យួនគេ មានពត់ គឺថា គេមានគោលការណ៍គេច្បាស់ សំរាប់បោកប្រាស់ខ្មែរ ទៅតាមកាលៈទេសៈ ដែលមានកើតឡើង សំរាប់គេអាចទាញ យកជា ប្រយោជន៏បាន ពីការចែចូវ របស់ខ្មែរ។ ដូច បច្ចុប្បន្នកាលនេះ មានពួកអាយ៉ងយួន, អ្នកចូលដៃយួន, អ្នកបង្គ្រប់កិច្ច, អ្នកហៃអើ នាំគ្នាបំរើយួន ឈ្លោះ នឹងប្រជាជាតិខ្លួនឯង ដើម្បីការពារប្រយោជន៏យួន ដោយចេតនា ឬ អចេតនា នាំគ្នាទុក អ្នកស្នេហាជាតិ ជាសត្រូវនឹងខ្លួន និយាយបោកប្រាស ប្រជាជនខ្មែរ ដែលកំពុង លង់ទឹក ឃើញអ្វី ប្រតោងក្ដាម ឲតែបានរស់ ពីមួយថ្ងៃទៅមួយថ្ងៃ ដែលខ្មែរយើង និយាយថា រស់សំរាប់មួយគែ។ ឆ្លៀតយក សម្រេកជីវិតនេះ នាំគ្នាប្រមូលកម្លាំងអ្នកឈឺចិត្ត នឹងរបបផ្ដាច់ការ តែមិនយកវាទៅកិន បំបែកអំណាចផ្ដាច់ការ បែរ ជាយកវា ទៅ ធានា ការពារសេចក្ដីសុខ ឲវាទៅវិញ ដោយយកពាក្យអហឹង្សាសំរាប់គេចវេះ ពីសេចក្ដីពិត គឺគោលបំណង ចង់ចែកអំណាច ជាមួយពួកអាយ៉ងយួន តាមការចរចារ។ ប្រវត្តិសាស្ត្រខ្មែរ បានបង្ហាញច្បាស់ណាស់ថា ជាមួយយួនមានពត់ បើខ្មែរយើង ធ្វើអ្វីខុសមួយ ចំពោះជាតិខ្លួនឯង គឺវា ច្បាស់ជាក្លាយជាចំណី សំរាប់ចិញ្ចឹមយួន ឲបានធំធាត់ភ្លាម។ ស្ថានភាព នៃស្រុកខ្មែរសព្វថ្ងៃនេះ គឺកើតមក ពីការបូកចូលគ្នា នូវកំហុសដែលអ្នកដឹកនាំជាតិ ហើយនឹង ប្រជាជនខ្មែរយើង បានប្រព្រឹត្ត រាប់សត្តវត្សរួចមកហើយ ដូច្នេះ បើខ្មែរយើង នៅតែមិនស្គាល់កំហុសខ្លួនឯង មិនស្គាល់សត្រូវជាតិខ្លួនឯងឲច្បាស់ គឺជាតិខ្មែរកំពុងធ្វើដំណើរបន្តទៅរកជ្រោះមរណៈជាពុំខាន។ ខ្មែរត្រូវរំលឹងជានិច្ច ហើយចារទុកក្នុងសតិ នូវបុរាណភាសិតខ្មែរថា៖ «សៀមមិនចោលក្បួន, យួនមិនចោលពត់, ខ្មែរមិនចោលចែចូវ» ព្រោះជាបណ្ដាំចង្អុលប្រាប់ខ្មែរជាន់ក្រោយ ថាផ្លូវមរណៈខ្មែរ គឺចរិតខ្មែរយើងនោះឯង ដែលបានរៀបរាប់ យ៉ាងក្បោះក្បាយ ពីសំណាក់ លោក បុណ្ណ-ចន្ទ-ម៉ុល នៅក្នុងសៀវភៅរបស់លោក។ បើខ្មែរយើង មិនដូរចរិត ជាអវិជ្ជមាន បាននោះទេ ដូច្នេះ កុំនាំគ្នាខឹង នឹង យួន/សៀម ព្រោះថា គេខ្លាំងបាន ដោយសារយើងខ្សោយនេះឯង។ ពុទ្ធដីកា៖ «**អត្តាហិ អត្តនោ នាថោ**» ប្រែថា «**ខ្លួនទីពឹងខ្លួន**» គឺជាជន្លួញមួយ ដែលរុញឲមនុស្ស ឲខិតខំប្រឹងគិតពិចារណា ដើម្បីរំដោះខ្លួនពីទុក្ខក្នុងលោកនេះ។ ចំពោះខ្មែរយើង ដែលជាអ្នកកាន់ពុទ្ធសាសនា គួរ ដឹងយល់ថា បើចង់រំដោះជាតិ ពីរបបផ្ដាច់ការ គឺមានតែមធ្យោបាយ ខ្លួនទីពឹងខ្លួន នោះឯង រំដោះដើម្បីកសាងលទ្ធិប្រជាធិបតេយ្យ ដែលជាទ្រឹស្ដីមួយ ស្ដីពី អភិបាលកិច្ចរបស់ប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ និង ដើម្បីប្រជាពលរដ្ឋ, ដូច្នេះ គ្មានអ្វីប្រសើរជាងលទ្ធិនេះឡើយ៕

[2] ចែចូវ (វចនានុក្រមខ្មែរ ផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ) = ដែលប៉ុនខាងនិយាយដើមគេ, ដែលប៉ុនខាងពោលពាក្យញុះញង់។ ន័យទី១គឺ នាំសំដីទៅមក ប្រើសំរាប់ មុននឹងដណ្ដឹងកូនក្រមុំគេ ត្រូវឲមនុស្សទៅចែចូវសិន។